**ធម្មទេសនារបស់លោកអភិបាល អូលីវីយេ**
**អភិបូជាជាមួយបព្វជិតបព្វជីតាទាំងអស់**
**ភ្នំពេញថ្មី ថ្ងៃទី០៧ ខែមករា ឆ្នាំ២០២០**

# តើយើងធ្វើដូចម្ដេចដើម្បីប្រកាសដំណឹងល្អ?

**អត្ថបទទី១៖ យ៉ូហានទី១ ៤,៧-១០**

រីឯអ្នកដែលមិនចេះស្រឡាញ់ មិនបានស្គាល់ព្រះជាម្ចាស់ទេ ដ្បិតព្រះជាម្ចាស់ជាសេចក្ដីស្រឡាញ់។ ១យហ ៤,៨

**ដំណឹងល្អ៖ ម៉ាកុស ៦,៣៤-៤៤**

ព្រះយេស៊ូមានព្រះបន្ទូលតបទៅគេវិញថា៖ «ចូរអ្នករាល់គ្នាយកម្ហូបអាហារឲ្យគេបរិភោគទៅ!» ។ មក ៦,៣៧

បងប្អូនជាទីស្រឡាញ់!

ថ្ងៃនេះ យើងជាបព្វជិតបព្វជីតាជួបជុំគ្នាយើងរិះគិតអំពីសំណួរ **តើយើងធ្វើដូចម្ដេចដើម្បីប្រកាសដំណឹងល្អ?** ក្រុមគ្រីស្តទូតគេមើលឧបសគ្គដែលគេជួបនៅពេលមានមនុស្សជាច្រើនកំពុងឃ្លាន តែព្រះយេស៊ូមិនមើលបញ្ហានេះទេព្រះអង្គសួរថាមានអ្វីខ្លះ? ប្រសិនបើយើងមើលនំប៉័ង៥ដុំនិងត្រី២កន្ទុយ ដើម្បីចិញ្ចឹមមនុស្សរាប់ពាន់នាក់យើងគិតថាមិនអាចធ្វើបានទេ។ ប៉ុន្តែ ឲ្យយើងទុកចិត្តលើព្រះយេស៊ូទៅ ព្រះអង្គយាងមកដើម្បីណែនាំឲ្យយើងមានសុភមង្គល ដើម្បីផ្តល់កម្លាំងកាយកម្លាំងចិត្តឲ្យយើងចូលនៅក្នុងគម្រោងការដ៏អស្ចារ្យ របស់ព្រះអង្គគឺចាប់កំណើតជាមនុស្សដើម្បីធ្វើដំណើរជាមួយយើង។ ឧបសគ្គ មិនអាចទៅជាអ្វីដែលរាំងផ្លូវរបស់យើង ឧបសគ្គយើងត្រូវតែជួបប៉ុន្តែឲ្យយើងមើលព្រះយេស៊ូនៅលើឈើឆ្កាង ឲ្យយើងផ្ញើទៅព្រះយេស៊ូចុះព្រះអង្គនឹងរកមធ្យោបាយដើម្បីឲ្យយើងទៅមុខ។

បេសកកម្មរបស់យើង ដូចក្នុងគម្ពីរដំណឹងល្អ "**ចូរអ្នករាល់គ្នាយកម្ហូបអាហារឲ្យគេបរិភោគទៅ**" នេះជាព្រះបន្ទូលដែលត្រូវការដឹកនាំបេសកកម្មរបស់យើងជាអ្នកប្រកាសដំណឹងល្អ។ ឲ្យយើងចិញ្ចឹមគេទៅ កុំឲ្យយើងចេះតែនិយាយ ព្រះយេស៊ូមិនគិតតែពីអប់រំគេព្រះអង្គចេះមើលគេឃ្លាន។ ព្រះយេស៊ូក្នុងជីវិតរបស់ព្រះអង្គ ពេលគេឃ្លានព្រះអង្គឲ្យម្ហូបទៅគេបរិភោគ ពេលគេឈឺព្រះអង្គព្យាបាលគេឲ្យបានជាសះស្បើយ ពេលគេស្លាប់ព្រះអង្គប្រទានឲ្យគេរស់ឡើងវិញ។ នេះជាអ្វីដែលត្រូវដឹកនាំគ្រប់គម្រោងការរបស់យើង ឲ្យយើងឆ្លើយតបដល់សេចក្ដីត្រូវការរបស់គេដែលណែនាំឲ្យយើងចូលនៅក្នុងជីវិតរបស់គេយ៉ាងជ្រៅ។ ព្រះយេស៊ូមិនតែឲ្យម្ហូបហើយឈប់ព្រះអង្គបានណែនាំអប់រំ បានធ្វើដំណើរជាមួយគេ ឲ្យគេលះបង់ចោលអ្វីៗទាំងអស់ប្រសិនបើគេចង់ដើរតាមព្រះអង្គ។ ព្រះយេស៊ូ មានមួយកំភ្លេរនៅក្នុងការប្រកាសដំណឹងល្អ ការអប់រំ ឆ្លើយតប

សេចក្តីត្រូវការ និងអធិដ្ឋាន។ ពេលយើងចង់ប្រកាសដំណឹងល្អក្នុងដួងចិត្តបងប្អូន ឲ្យយើងមានមួយកំភ្លេរដូចព្រះយេស៊ូ ដើម្បីណែនាំឲ្យមនុស្សដែលធ្វើដំណើរជាមួយយើងបន្តិចម្តងៗ អាចកសាងគ្រួសារមួយយ៉ាងជិតស្និទ្ធជាមួយព្រះយេស៊ូ។

ព្រះជាម្ចាស់ជាសេចក្តីស្រឡាញ់ នៅក្នុងសៀវភៅគម្ពីរ៧៣ក្បាលដែលយើងមាន មានតែម្តងគត់ដែលយើងបានស្តាប់គឺ "**ត្បិតព្រះជាម្ចាស់ជាសេចក្តីស្រឡាញ់**"។ ពេលយើងចូលនៅក្នុងលក្ខណៈជាសេចក្តីស្រឡាញ់ យើងយល់អំពីជីវិតរបស់យើង យើងត្រូវស្រឡាញ់គ្នាទៅវិញទៅមកព្រោះសេចក្តីស្រឡាញ់មកពីព្រះជាម្ចាស់។ នេះជាជីវិតរបស់បព្វជិតបព្វជីតា ជាជីវិតរបស់អ្នកដឹកនាំព្រះសហគមន៍ គឺបង្ហាញធម៌មេត្តាករុណារបស់ព្រះជាម្ចាស់នៅក្នុងជីវិតរបស់យើងផ្ទាល់។ នៅក្នុងទុក្ខលំបាក នៅក្នុងអំណរសប្បាយរបស់យើង យើងមានសេចក្តីស្រឡាញ់ដែលផុសចេញដើម្បីណែនាំឲ្យគេដឹងថា យើងជាបងប្អូនដែលចេះស្រឡាញ់គ្នាទៅវិញទៅមក។ នេះជាសក្ខីភាពដែលយើងផ្តល់លើសពីអ្វីៗទាំងអស់ ទំនាក់ទំនងដែលយើងមានជាមួយបងប្អូន បើទំនាក់ទំនងនេះពោរពេញដោយសេចក្តីស្រឡាញ់ដែលមកពីព្រះជាម្ចាស់ យើងដឹងថានេះជាសក្ខីភាពដែលយើងបានផ្តល់។ ផ្លែដែលយើងទទួលយើងមើលមិនសូវឃើញ ប៉ុន្តែឲ្យយើងខិតខំសាបព្រោះសេចក្តីស្រឡាញ់នេះ។

បងប្អូនជាទីស្រឡាញ់ យើងជាអ្នកកសាងព្រះសហគមន៍នៅក្នុងភូមិភាគភ្នំពេញ ឲ្យយើងយកចិត្តទុកដាក់ដើម្បីឲ្យអ្នករាល់គ្នាមានម្ហូបអាហារញ៉ាំបរិបូណ៌ ដោយរស់នៅក្នុងសេចក្តីស្រឡាញ់ដែលមកពីព្រះជាម្ចាស់។ យើងដឹងថាពេលព្រះសហគមន៍របស់យើងរីកចម្រើន ពេលជីវិតរបស់យើងរីកចម្រើន នោះបងប្អូនឯទៀតៗអាចរកឃើញសុភមង្គលដ៏ពិតប្រាកដតាមរយៈយើង។ អាម៉ែន៕